ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០២១

នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធវីដេអូ ផ្សាយចេញពីវិមានព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់៖

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ

២-សេចក្តីព្រាងច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពី ការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់

- បានរៀបចំចាត់ចែងប្រជុំតាមប្រព័ន្ធវីដេអូ ជាមួយនឹងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២២ របស់ព្រឹទ្ធសភា

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំស្តីពី ការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូផ្សាយចេញពីរដ្ឋសភា

- បានទទួលព្រះរាជក្រឹត្យ សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន២៥ច្បាប់

-បានបញ្ចប់ការសិក្សាស្រាវជ្រាវ និងព្រាងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០៦ច្បាប់

-កំពុងសិក្សាស្រាវជ្រាវ និងបន្តរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ សេចក្តីសម្រេច របាយការណ៍ និងលិខិតផ្សេងៗចំនួន២២ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ៗ

**៣- មុខងារតំណាង**

- បានផ្តល់សេវាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមពិធីដង្ហែព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ស្តេចយាងទៅកាន់ទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងបានអញ្ជើញផ្តល់ភ្លើងបូជាសព **ឯកឧត្តម សុខ យាត** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី ខេត្តព្រៃវែង

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ចុះពិនិត្យមណ្ឌលព្យាបាល និងចត្តាឡីស័កអ្នកជំងឺកូវីដ-១៩ ព្រមទាំងនាំយកគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ជាពិសេសប្រជាពលរដ្ឋដែលកំពុងមានជំងឺកូវីដ-១៩ ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានបំពេញភារកិច្ចផ្សេងៗទៀតនៅមូលដ្ឋាន រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៨៧លើក

- បាននាំយករទេះសម្រាប់ជនពិការ ផ្តល់ជូនចាស់ជរាចំនួន០៣រូប ដែលមានជំងឺប្រចាំកាយ

ស្ថិតនៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល ព្រមទាំងបាននាំយកស្បៀងអាហារដែលជាអំណោយរបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ជូនដល់សមាគមតន្ត្រីសំនៀងជនពិការដែលកំពុងជួបការខ្វះខាត ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩

- បានរៀបចំ និងចាត់ចែងពិធីបុណ្យសព និងបូជាសព **ឯកឧត្តម សុខ យាត** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី ភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

- បាននាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩ចំនួន០៤នាក់ និងកំពុងធ្វើចត្តាឡីស័កចំនួន០១នាក់

- បានទទួលម៉ាស់ចំនួន៥,០០០ម៉ាស់ ជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩

- បានទទួលពាក្យបណ្តឹងចំនួន០៦ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៦ករណី និងកំពុងពិនិត្យសិក្សាចំនួន០៦ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០២ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន០២ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០៤ករណី

- បានផ្ញើសាររំលែកទុក្ខជូនសមាជិកព្រឹទ្ធសភា និងឥស្សរជននានាចំនួន០៤លើក

- បានផ្ញើលិខិតអបអរសាទរជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលសម្តេចទទួលគ្រឿងឥស្សរិយយសថ្នាក់ "មិត្តភាព Order of Friendship" ពីឯកឧត្តម **Vladimir Putin** ប្រធានាធិបតីនៃសហព័ន្ធរុស្ស៊ី

- បានផ្ញើសារលិខិតជូនពរ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំង**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងឱកាសចម្រើនជន្មាយុ

- បានរៀបចំអំណោយជូនគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិចំនួន៣០កញ្ចប់

- បានផលិតទស្សនាវដ្តីប្រចាំខែសីហា ឆ្នាំ២០២១ ចំនួន៨០០ក្បាល។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យតំណាងបេក្ខជនជ័យលាភីអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្សរបស់ជប៉ុន(JDS)ឆ្នាំ២០២០ ចំនួន០៣នាក់ ចូលជួបសម្តែងការគួរសម

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ចូលរួមក្នុងពិធីបើក និងពិធីបិទនៃមហាសន្និបាតអន្តរសភាអាស៊ាន(AIPA) លើកទី៤២, កិច្ចប្រជុំគណៈកម្មាធិការអេចិត្រៃ្តយ៍ទទួលបន្ទុកថវិកា និងផែនការនៃសភាតំបន់អាស៊ី(APA), កិច្ចប្រជុំរបស់គណៈកម្មការរៀបចំកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ (ASEP11) តាមប្រព័ន្ធវីដេអូ

- បានបង្កើតក្រុមមិត្តភាពព្រឹទ្ធសភាជាមួយព្រឹទ្ធសភាប៉ាគីស្ថាន និងក្រុមព្រឹទ្ធសភាទទួលបន្ទុក (ASEP)

- បានសម្របសម្រួលជាមួយស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ទទួលឱសថបុរាណចិន "LIANHUA QINGWEN" ចំនួន៤០០ប្រអប់ និងបានចែកជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានផ្ញើលិខិតថ្លៃងអំណរគុណជូនស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែសីហាចំនួន០១ច្បាប់

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិចំនួន៥៩អត្ថបទ

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច(CDC), វិទ្យាស្ថានសភាអាស៊ី(PCA), វិទ្យាស្ថានសាន់ហ៉យស៍, វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- សហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសជំរុញ (ដូសទី៣) ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំបែបបទ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ស៊ីណូវ៉ាក់ ដូសទី១) ជូនក្រុមគ្រួសារសមាជិកព្រឹទ្ធសភា ដែលមានអាយុចាប់ពី១២ឆ្នាំ ដល់អាយុ១៨ឆ្នាំ

- បានរៀបចំបញ្ជីឈ្មោះមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានជំងឺកូវីដ-១៩ និងជាសះស្បើយចំនួន១៥នាក់

- បានទទួលលិខិតចូលចំនួន១៨៣ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២៣ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការថែរក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន

- ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាឆ្នាំ២០២១

- បានប្រជុំកម្រិតនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២

- បានប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មី

- បានបើកប្រាក់បៀវត្សប្រចាំខែសីហា និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែសីហា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណចេញ-ចូលក្នុងបរិវេណព្រឹទ្ធសភាចំនួន២១ប័ណ្ណ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន០៩ច្បាប់

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន១១នាក់

- បានធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិតមធ្យម និងជំនាញទំនាក់ទំនង

- បានចាប់ផ្តើមកសាងបន្ទប់អានសម្រាប់បណ្ណាល័យអេឡិចត្រូនិច និងបំពាក់សម្ភារ

- បន្តសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន១០បួង ព្រមទាំងកាត់ដើមឈើនៅអគារស្នាក់នៅរបស់អង្គភាពសន្តិសុខនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានជួសជុលប្តូរម៉ាបបង្កាន់ដៃអគារខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា

- បានធ្វើ Background ក្តារ(MC) ជូនគណៈកម្មការទី១, ទី២, ទី៣, ទី៤, ទី៦, ទី៩, និងសាល

ពិសេសនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៩៤គ្រឿង/លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus និងSetup Window Printer Program Ipad ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៣៦គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៩៣ប្រធានបទ

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

II-**លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨១ច្បាប់

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៤លើក

- បានតុបតែងលម្អ និងតាំងពិព័រណ៍រូបភាពចំនួន០៦លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៦ច្បាប់ ស្មើនឹង១៦នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៩៩លើក

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈអាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៩លើក មានអ្នកចូលរួមចំនួន១៧៣នាក់

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ

ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន៣១សំណើ

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៩៥លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន១១សំណើ អស់ក្រដាសចំនួន១៣,៥៨៦សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៥២លើក ស្មើនឹង៦០នាក់។ បានជួសជុល និងប្តូរប្រេងម៉ាស៊ីនរថយន្តចំនួន០៧គ្រឿង

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែកក្កដាចំនួន០៤ច្បាប់

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៣លើក ព្រមទាំងបានផលិតខ្សែវីដេអូស្តីពី ពិធីបុណ្យសព និងបូជាសព **ឯកឧត្តម សុខ យាត** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា ជូនក្រុមគ្រួសារសព

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន២,៣២២លើក

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៤លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២១លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០២លើក។

## III-ទិសដៅការងារខែកញ្ញា ឆ្នាំ២០២១

-ការគំរាមកំហែងបន្តនៃជំងឺកូវីដ-១៩ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta) ដែលកំពុងបន្តអូសបន្លាយ បានបង្កផលប៉ះពាល់ជាអវិជ្ជមាន សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន

-អនុវត្តវិធានសុខាភិបាលថ្មីតាមរយៈការចាក់វ៉ាក់សាំងលើកទី៣ (ដូសជំរុញ) បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតឡុកដោន) ប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងពេលវេលាថ្មីដែលមេរោគប្រភេទដែលតា(Delta) កំពុងរាលដាល និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និង

ក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមលក្ខណៈនៃការវិលត្រលប់មកកាន់ភាពប្រក្រតីនៃការអនុវត្តមុខងារស្នូលទាំង៣៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

+បច្ចុប្បន្នភាពក្បាលម៉ាស៊ីនដឹកនាំគ្រប់គ្រង ដែលទំនេរដោយមូលហេតុនៃការចូលនិវត្ត

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ វត្តមានមន្ត្រី បុគ្គលិកត្រូវបន្តឈរលើគោលការណ៍វត្តមានតិចបំផុត២% តែអាចបង្កើនបាន បើមានការចាំបាច់បន្ទាន់ ឬសំខាន់បំផុត៖**

+ធានាថាសម័យប្រជុំលើកទី៧ នីតិកាលទី៤ បានប្រព្រឹត្តទៅដោយរលូន ទាន់ពេលវេលា ល្អ និងមានលទ្ធផលផ្លែផ្កា ហើយអនុលោមបានតាមលក្ខខណ្ឌកូវីដ-១៩ ដោយកាត់បន្ថយបរិមាណអ្នកចូលរួម និងបង្កើនគុណភាពនៃការធ្វើតេស្តរហ័ស ហើយពេលខ្លះរៀបចំប្រជុំគណៈកម្មា-ធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ឬក្រុមពីចម្ងាយ។ ចាត់ចែងផ្តល់សេវាស្រាវជ្រាវ ឯកសារជំនួយស្មារតី សេចក្តីប្រកាសព័ត៌មាន លិខិតអញ្ជើញ លិខិតឆ្លើយឆ្លង បច្ចេកទេស និងនីតិវិធី និងកិច្ចប្រជុំពាក់ព័ន្ធច្រើនកម្រិត (គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការនានា ប្រជុំក្រុម និងពេញអង្គ) ធ្វើបានល្អ រលូន ទាន់ពេលវេលា និងមានការចូលរួមដោយសកម្ម

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ

ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

**-ត្រៀមប្រកាសសមាជិកព្រឹទ្ធសភាថ្មីជំនួស ឯកឧត្តម សុខ យាត សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា ធ្វើបច្ចុប្បន្នភាពក្រុមនានា ក្រោយការផ្លាស់ប្តូរថ្មី (ការផ្តល់ការិយាល័យ ស្វាករថយន្ត ប័ណ្ណសមាជិក និងរបបមូលដ្ឋានសម្រាប់សមាជិកថ្មី)។**

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំពេញអង្គព្រឹទ្ធសភានីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៧ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់

២-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨ថ្មី នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

៤-សេចក្តីព្រាងច្បាប់ស្តីពី ការប្រកួតប្រជែង

៥-សេចក្តីព្រាងច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

៦-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពី ការងារដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

៧-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពី ការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារ និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន និងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ

និងតាមបណ្តាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកព្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត វេទិកានានា ការងារពិធីការជាតិ និងស្ថាប័ន កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែន ជាការតម្រូវនៃបរិបទកូវីដ-១៩៖

+ផ្តោតអាទិភាពលើការរៀបចំប្រជុំ (ASEP), (CLV) និង(AIPA) ដែលសភាកម្ពុជាជាម្ចាស់ផ្ទះ។ សហការរៀបចំវគ្គសិក្សា២ ដែលព្រឹទ្ធសភាត្រូវរៀបចំជាមួយ(APF) នាចុងខែតុលា និងដើមខែវិច្ឆិកា ព្រមទាំង(ITECH), (MFA)...ចាប់ពីខែសីហា។ តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ជាមួយឥណ្ឌា និងប៉ាគីស្ថាន កម្មវិធីវិទ្យាស្ថានក្រសួងការបរទេស និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ឡើងវិញជាមួយដៃគូសំខាន់ៗរបស់(PCA) ជាមួយរដ្ឋសភា ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)។ តាមដានការអនុវត្តជំនួយចិន សម្រាប់បណ្ណាល័យអេឡិចត្រូនិច និងគម្រោងអភិវឌ្ឍបច្ចេក-វិទ្យាព័ត៌មាន

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំហានដំបូង

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-ការឈានទៅបង្កើតក្រុមជាតិ(ASEP) រវាងរដ្ឋសភា និងព្រឹទ្ធសភា។ ការធ្វើបច្ចុប្បន្នភាពក្រុមនានាក្រោយការផ្លាស់ប្តូរសមាជិកព្រឹទ្ធសភា

-ត្រៀមបែបបទចាំបាច់សម្រាប់ការរៀបចំប្រជុំ (ASEP) នាខែវិច្ឆិកាខាងមុខ និងការងារត្រៀមប្រជុំ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការ

ចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA, ASEP...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការបញ្ចប់ផែនការការងារដំណាច់ឆ្នាំ បូកសរុប និងលើកទិសដៅឆ្នាំថ្មី

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-រយៈពេលបង្កើនការរឹតខ្សែក្រវ៉ាត់ ដោយវិធានការរិចារណកម្មថវិកា ក្នុងឆមាសទី២ ឆ្នាំ២០២១, ការកសាងថវិកាឆ្នាំថ្មី២០២២ ដោយគិតដល់តម្រូវការក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ ក្នុងឆមាសទី១ ឆ្នាំ២០២២៖ សម្ពាធនៃតម្រូវការអនុវត្តភាពតំណាងរបស់ព្រឹទ្ធសភា អនុវត្តស្វែងរកជំនួយចិន និងដៃគូ ដើម្បីចាប់ផ្តើមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន បន្ទាប់ពីមជ្ឈមណ្ឌលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ត្រូវបានសាងសង់រួច

-ការត្រៀមរៀបចំបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែកញ្ញា និងបុណ្យភ្ជុំបិណ្ឌ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+សមត្ថភាពដឹកនាំ គ្រប់គ្រងនៅតែជាតម្រូវការបន្ទាន់ អាស្រ័យដោយកន្លែងខ្វះ អ្នកត្រូវបន្តវេននៅរកពុំទាន់បានតាមតម្រូវការនៃមុខតំណែង

+ធ្វៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

+រកវិធានការដោះស្រាយបញ្ហាទឹកលិច ដោយសហការជាមួយសាលាក្រុង និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អនុវត្តការងារ៤ខែចុងឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាពកសាងថវិកាឆ្នាំ២០២២ លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២។ ការបូកសរុបលទ្ធផលការងារត្រីមាសទី៣ ឆមាសទី២ ប្រចាំឆ្នាំ និងការទូទាត់ថវិកាឆមាសទី១ និងប្រចាំឆ្នាំ ត្រូវអនុវត្តទាន់ពេលវេលាដោយស្មារតីទទួលខុសត្រូវ៖

+លើកគម្រោងវិភាជន៍គម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ដើម្បីថ្លឹងយោបល់សម្រេចក្នុងរបនាសម្ព័ន្ធរដ្ឋបាល និងនយោបាយ

+ការបោះពុម្ពទិនានុលេខន៍ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវជានាគុណភាព និងបរិមាណសមស្របកម្មវិធីបុណ្យជាតិ(បុណ្យឯករាជ្យ) បុណ្យប្រពៃណី(ភ្ជុំបិណ្ឌ កឋិនទាន) និងកម្មវិធីផ្សេងៗទៀតត្រូវជានាការអនុវត្តឱ្យបានទាន់ពេលវេលា

+ជំរុញការកសាងខ្សែវីដេអូអំពីប្រវត្តិទីស្ថានអគារប្រវត្តិសាស្ត្ររបស់ព្រឹទ្ធសភា

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម៖ គោលការណ៍តមជ្រើសរើសថ្មីរហូតឆ្នាំ២០៣០ ការតម្លើងកាំប្រាក់ មុខតំណែង សន្ទស្សន៍បៀវត្សត្រូវរក្សាស្ថានភាពដដែលរហូតមានការណែនាំថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្ដុះបណ្ដាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា៖

+៥វគ្គជាមួយភាគីឥណ្ឌា

+វគ្គជាមួយ (PCA)

+វគ្គភាសាអង់គ្លេស ភាសាបារាំង និងថៃជាមួយក្រសួងការបរទេស

+វគ្គភាសាអង់គ្លេសជាមួយស្ថានទូតហ្វីលីពីន

+២វគ្គជាមួយលេខាធិការដ្ឋាន (APF) នាចុងខែតុលា និងដើមខែវិច្ឆិកា

-បញ្ចូលប្រើបច្ចេកវិទ្យា ឧបករណ៍បច្ចេកទេសប្រើអគ្គិសនី (រថយន្តសម្អាត រថយន្តសម្រាប់ឡើងទីខ្ពស់ រថយន្តប្រមូលសំរាម) ការប្រឈមដោះស្រាយបញ្ហាទឹកបន្តលិចផ្ទៃកខ្វះ ការបង្កើយអគារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ការចាប់ផ្ដើមការដ្ឋានបណ្ណាល័យអេឡិចត្រូនិច ការគ្រប់គ្រងសំរាម និងផ្លាស្ទិក ការរក្សាអនាម័យ និងសួនតាមរបៀបថ្មី របៀបគិត រស់នៅ និងធ្វើការតាមគន្លងថ្មីក្រោមការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងតាមរបៀបប្រែប្រួលអាកាសធាតុ (ដែលកាន់

តែក្តៅ កខ្វក់ និងក្រទឹក) ធម្មជាតិប្រែប្រួលតាមរយៈគម្រោងតូចៗ (Pilot Project)។ បច្ចេកវិទ្យាព័ត៌មានកខ្វក់ (ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ ស្តុកទិន្នន័យ)។ ជំងឺកូវីដ-១៩ មានការគំរាមកំហែងខ្វះដល់បរិស្ថានផងដែរ។ ពិចារណាការប្រើប្រាស់កម្លាំងពលកម្មឱ្យបានសមស្របដំណាក់កាលថ្មីដែលមានការប្រែប្រួលជារៀងរាល់ថ្ងៃ។

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មីវិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-ត្រៀមរៀបចំចងក្រងសៀវភៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំថ្មី

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងជំនួយចិនក្នុងការសាងសង់ និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានាៗល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែសីហានេះ ក្នុងបរិបទដែលកម្ពុជាកំពុងប្រឈមនឹងការមកដល់នៃរលកទី៣ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា(Delta) រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ "យុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" នៅទូទាំងប្រទេស។ ដើម្បីឆ្លើយតបនឹងយុទ្ធនាការនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បង្កើនការយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋាន បានរៀបចំ និងចាត់ចែងការប្រជុំស្តីពី គម្រោងថវិកាឆ្នាំ២០២២ របស់ព្រឹទ្ធសភា។ ចំពោះមុខងារតំណាង បានបំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្តែង ប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន ដោយផ្តោតការយកចិត្តទុកដាក់ចុះតាមមូលដ្ឋាន ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន

ឈ្វេងយល់អំពីសុខទុក្ខ ដោះស្រាយបញ្ហាប្រឈម និងចូលរួមគោរពវិញ្ញាណក្ខន្ធសព ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក នៅរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា។ លើមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានចាត់ចែងការចូលរួមកិច្ចប្រជុំ(AIPA), (APA )តាមប្រព័ន្ធវីដេអូ។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ និងចូលរួមចាក់វ៉ាក់សាំងដូសទី៣ ដែលជាដូសជំរុញឱ្យបានគ្រប់ៗគ្នា។

ព្រឹទ្ធសភានឹងបន្តសម័យប្រជុំលើកទី៧ នីតិកាលទី៤ ដើម្បីអនុម័តរបៀបវារៈសំខាន់ចំនួន ០៧ច្បាប់ ព្រមទាំងប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នាពេលខាងមុខ។

ថ្ងៃ ៧ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២១

**អគ្គលេខាធិការ**

**អ៊ុំ_សារិទ្ធ**